# សុន្ទរកថា
# របស់អគ្គលេខា ប្រធានារដ្ឋ ង្វៀនភូត្រុង ក្នុងពិធីខួបរំលឹកអនុស្សាវរីយ៍៩០ ឆ្នាំនៃថ្ងៃបង្កើតបក្សកុម្មុយនិស្តវៀតណាម

*អង្គប្រជុំជាទីគោរព*

*សមមិត្តនិងជនរួមជាតិជាទីគោរពនិងជាទីមេត្រី*

នៅក្នុងបរិយាកាសប្រទេសទាំងមូលរីករាយចំពោះសមិទ្ធិផលសំខាន់ៗជាច្រើននៃឆ្នាំ ២០១៩ និងស្វាគមន៍ឆ្នាំថ្មីឆ្នាំជូត ២០២០ ហើយថ្ងៃនេះនៅរដ្ឋធានីហាណូយ "អរិយធម៌ដ៏រាប់ពាន់ឆ្នាំ និងវីរៈក្រុង"-" ទីក្រុងដើម្បីសន្តិភាព" យើងរៀបចំយ៉ាងឧឡារិកនូវខួបរំលឹកអនុស្សាវរីយ៍លើកទី ៩០ នៃថ្ងៃបង្កើតបក្សកុម្មុយនិស្តវៀតណាមរុងរឿង *(៣ កុម្ភៈ ១៩៣០-ថ្ងៃទី ៣ ខែកុម្ភៈឆ្នាំ ២០២០)* ។

តាងនាមគណៈកម្មាធិការមជ្ឈឹមបក្ស ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅនិងផ្ញើជូនដល់ថ្នាក់ដឹកនាំ អតីតថ្នាក់ដឹកនាំបក្ស រដ្ឋ រណសិរ្សមាតុភូមិវៀតណាម អតីតយុទ្ធជនបដិវត្ត និងអ្នកម្តាយវីរជនវៀតណាម បណ្តាភ្ញៀវកិត្តិយស សមមិត្តទាំងអស់ជនរួមជាតិទូទាំងប្រទេស និងជនជាតិវៀតណាមនៅក្រៅប្រទេស ការសាកសួរសុខទុក្ខ និង សព្ទសាធុការពរជ័យដ៏មហាប្រសើបំផុត។

*សមមិត្តនិងជនរួមជាតិជាទីគោរពជាទីមេត្រី*

ប្រវត្តិសាស្ត្ររាប់ពាន់ឆ្នាំនៃប្រជាជាតិយើងបានបង្ហាញថាស្នេហាជាតិ និងការពារប្រទេស ការតស៊ូប្រយុទ្ធប្រឆាំងប្តូរផ្តាច់នឹងពួកឈ្លានពាន ការពារឯករាជ្យ អធិបតេយ្យភាព និងឯកភាពប្រទេសគឺជាប្រពៃណីដ៏មានតម្លៃរបស់ប្រជាជនយើង។

បន្តប្រពៃណីនោះ ចាប់ពីពាក់កណ្តាលសតវត្សរ៍ទី ១៩ នៅពេលដែលពួកអាណានិគមនិយមបារាំងចូលឈ្លានពានប្រទេសយើង ដោយខុសចិត្តភាពជាទាសករ ប្រជាជន យើងបានក្រោកឈរឡើងតស៊ូបន្តបន្ទាប់តាមរយៈចលនាស្នេហាជាតិដែលបានកើតឡើងជាបន្តបន្ទាប់និងខ្លាំងខ្លាតាមមធ្យោបាយជាច្រើនដែលមានមាគ៌ា និងនិន្នាការខុសគ្នាជាច្រើន។ ពីមាគ៌ាសង្គ្រោះប្រទេសជាតិរបស់បណ្តាអ្នកប្រាជ្ញស្នេហាជាតិហូតដល់បណ្តាការក្រោកឈរឡើងរបស់កសិករនិងមាគ៌ាបដិវត្តមូលធន។

ថ្វីត្បិតបានតស៊ូយ៉ាងស្វាអង់អាចមនសិការ និងទទួលរងនូវការលះបង់ជាច្រើន ប៉ុន្តែដោយសារកំណត់ប្រវត្តិសាស្ត្រ ជាពិសេសកង្វះមាគ៌ាដឹកនាំត្រឹមត្រូវ បណ្តាចលនាទាំងនោះមិនទទួលជោគជ័យឡើយ។ ប្រវត្តិសាស្ត្រតម្រូវឱ្យស្វែងរកផ្លូវថ្មី។

ក្នុងឆ្នាំ ១៩១១ យុវជនស្នេហាជាតិង្វៀនទឹតថាញ់ (គឺប្រធាន ហូជីមិញជាទីគោរពស្រឡាញ់របស់យើង) បានចាកចេញដើម្បីស្វែងរកផ្លូវថ្មីសម្រាប់បុព្វហេតុនៃការសង្គ្រោះជាតិនិងតស៊ូដើម្បីដណ្ដើមឯករាជ្យជាតិ។

ដោយក្នុងចិត្តមានបំណងប្រាថ្នាមហិច្ឆតាវ្យយ៉ាងធំធេង និងកក់ក្ដៅ លោកប្រធានហូជីមិញបានសិក្សារលិទ្ធិម៉ាក្ស - លេនីនដែលបានរកឃើញនៅក្នុងទ្រឹស្ដីបដិវត្តនេះផ្លូវសង្គ្រោះប្រទេសជាតិត្រឹមត្រូវ ផ្លូវបដិវត្តអធន ។

បន្ទាប់ពីបានធ្វើសក្មភាពនៅក្រៅវប្រទេសអស់រយៈពេលជាច្រើនឆ្នាំលោកប្រធានហូជីមិញបានព្យាយាមសិក្សាស្រាវជ្រាវអនុវត្តប្រកបដោយភាពច្នៃប្រឌិត និងផ្សព្វផ្សាយបន្តិចម្ដង ៗនូវលទ្ធិម៉ាក្ស - លេនីនដល់ប្រទេសវៀតណាមហើយខិតខំធ្វើការរៀបចំលក្ខខណ្ឌចាំបាច់សម្រាប់ការបង្កើត បក្សបដិវត្តបរិសុទ្ធមួយ។ នៅថ្ងៃទី ៣ ខែកុម្ភៈឆ្នាំ ១៩៣០ សន្និសីទនៃការបង្រួបបង្រួមបណ្ដាអង្គការកុម្មុយនិស្តប្រជុំនៅឧបទ្វី កូលូននៅហុងកុង (ប្រទេសចិន) ក្រោមការដឹកនាំរបស់លោកប្រធានហូជីមិញ (មគ្គុទេសង្វៀនអាយហ្គួក) បានសំរេចចិត្តបង្រួបបង្រួមបណ្ដាអង្គការកុម្មុយនិស្តនៅក្នុងប្រទេសរបស់យើងក្លាយទៅជា បក្សតែមួយដែលមានឈ្មោះថាបក្សកុម្មុយនិស្តវៀតណាម។ នេះជារបត់ប្រវត្តិសាស្ត្រដ៏សំខាន់មួយ បញ្ចប់វិបត្តិអូសបន្លាយអំពីការរៀបចំ និងមាគ៌ាដឹកនាំ នៃបដិវត្តវៀតណាម។

ការបង្កើតបក្សកុម្មុយនិស្តវៀតណាមគឺជាលទ្ធផលនៃការគួបផ្សំចលនាម៉ាក្ស- លេនីននិងចលនាកម្មករនិងចលនាស្នេហាជាតិ។ បង្ហាញថាវណ្ណៈកម្មករនៃប្រទេសវៀតណាមបានធំធាត់ហើយមានកម្លាំងគ្រប់គ្រាន់ដើម្បីបំពេញបេសកកម្មជាប្រវត្តិសាស្ត្រដឹកនាំបដិវត្ត។

គម្មវិធីនយោបាយដំបូងរបស់ បក្សបានអនុម័តនៅក្នុងសន្និសីទបង្កើតបក្សបានកំណត់មាគ៌ាមូលដ្ឋាននៃបដិវត្តវៀតណាមដោយឆ្លើយតបតម្រូវការចាំបាច់របស់ប្រទេសជាតិនិងសេចក្ដីប្រាថ្នារបស់ប្រជាជន។

ក្រោយពីកើតមកផ្សាភ្ជាប់សាច់ឈាមនឹងប្រជាជន ត្រូវប្រជាជន គាំទ្រនិងជឿជាក់ជាដាច់ខាត់ មានតែក្នុងរយៈពេល ១៥ ឆ្នាំបក្សរបស់យើងបានដឹកនាំការតស៊ូដើម្បីរំដោះជាតិនិងអនុវត្តចលនាបដិវត្តវត្តកំពូលទាំងបី គឺ ចលនាកំពូលបដិវត្តឆ្នាំ ១៩៣០-១៩៣១ ដោយឈានដល់ចលនាសូវៀត - ងេទីញ បដិវត្តទាមទារការរស់នៅប្រជាជននិងប្រជាធិបតេយ្យ (១៩៣៦-១៩៣៩) និងចលនាបដិវត្តរំដោះជាតិ (១៩៣៩- ឆ្នាំ ១៩៤៥) រហូតដល់ឆ្នាំ ១៩៤៥ នៅពេលដែលឱកាសបដិវត្តចាស់ទំបក្សកុម្មុយនិស្តវៀតណាមបានដឹកនាំប្រជាជនវៀតណាមទាំងមូលធ្វើសំរេចជ័យជំនះនៃបដិវត្តខែសីហាឆ្នាំ ១៩៤៥ " ភ្លូកទឹកភ្លូកដី" បង្កើតឡើងសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមនៅថ្ងៃទី ២ ខែកញ្ញាឆ្នាំ ១៩៤៥ (ឆ្នាំនេះយើងប្រារព្ធខួបលើកទី ៧៥ឆ្នាំ) ។

ក្រោយពេលសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមបានបង្កើត បដិវត្តត្រូវបានប្រឈមមុខនឹងការលំបាកនិងឧបសគ្គជាច្រើនហើយក្នុងពេលតែមួយបានប្រឈមមុខនឹង "សត្រូវអត់ឃ្លាន សត្រូវអនក្ខរកម្ម និងសត្រូវឈ្លានពានពីខាងក្រៅ" ។

ក្នុងកាលៈទេសៈគ្រោះអាសន្នបែបនេះបក្សបានដឹកនាំប្រជាជនយើងឆ្លងកាត់ជំនះស្ថានការណ៍ "ធ្ងន់ធ្ងរបំផុត»ការពារនិងកសាងរដ្ឋអំណាចក្មេងខ្ចីដោយម៉ឺងម៉ាត់និងរៀបចំយ៉ាងសកម្មនូវគ្រប់រូបភាពដើម្បីឈានទៅការតស៊ូប្រឆាំងនឹងពួកអាណានិគមបារាំង។

ដោយឈរលើមាគ៌ា " ប្រជាជនទាំងមូល" លើគ្រប់វិស័យ" យូរអង្វែង" ពឹងផ្អែកលើកម្លាំងខ្លួនផ្ទាល់ជាសំខាន់" ពង្រីកភាពប្រពៃណីសាមគ្គី ស្នេហាជាតិរបស់ប្រជាជាតិទាំងមូលបក្សបានដឹកនាំប្រជាជនធ្វើអោយបរជ័យរាល់ឧបាយកល ផែនការ ឈ្លានពានរបស់សត្រូវជាពិសេសជ័យជំនះក្នុងសង្គ្រាមរដូវរងារ និងនិទាឃរដូវឆ្នាំ ១៩៥៣-១៩៥៤ ប្រកបដោយជ័យជំនះកំពូលនៅដៀនបៀនភូ ជាប្រវត្តិសាស្ត្រ "ល្បីល្បាញ់នៅទ្វីបទាំង ៥ និងរញ្ជួយផែនដី" បង្ខំឱ្យពួកអាណានិគមបារាំងត្រូវចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្រុងហ្សឺណែវ (ឆ្នាំ១៩៥៤) បញ្ចប់សង្គ្រាមឈ្លានពានវៀតណាម។

ចាប់ពីឆ្នាំ ១៩៥៤ ដល់ឆ្នាំ ១៩៧៥ ប្រទេសយើងត្រូវបានបែងចែកជាពីរភូមិភាគ។ ក្រោមការដឹកនាំរបស់បក្ស ភាគខាងជើងប្រឹងប្រែងយ៉ាងខ្លាំងក្នុងការកសាងសង្គមនិយមទន្ទឹមនឹងនោះបំពេញកាតព្វកិច្ចរបស់ខ្លួនចំពោះសមរភូមិខាងមុខហើយប្រជាជននៅភាគខាងត្បូងបានបន្តការតស៊ូប្តេជ្ញាចិត្តដើម្បីដណ្តើមឯករាជ្យជាតិនិងឯកភាពទឹកដី។

ឈរលើស្មារតី " លះបង់អ្វីៗទាំងអស់ប្រសើជាជាងការបាត់បង់ប្រទេស និងមិនព្រមធ្វើជាទាសករ" "គ្មានអ្វីដែលមានតម្លៃជាងឯករាជ្យភាពនិងសេរីភាព"; និងឈរលើមាគ៌ាត្រឹមត្រូវ និងប្រកបដោយការច្នៃប្រឌិតរបស់បក្ស ជាមួយកម្លាំងរួមរបស់ប្រជាជាតិទាំងមូលហើយកងទ័ពនិងប្រជាជនរបស់យើងបានធ្វើបរជ័យរាល់យុទ្ធសាស្ត្រសង្គ្រាមរបស់ចក្រពត្តិនិយមអាមេរិក រំដោះភាគខាងត្បូងទាំងស្រុង និងបង្រួបបង្រួមជាតិនៅថ្ងៃទី ៣០ ខែមេសាឆ្នាំ ១៩៧៥ ។

ជ័យជំនះនោះ" ត្រូវបានកត់ត្រាជារៀងរហូតក្នុងប្រវត្តិសាស្ត្រជាតិរបស់យើងថាជាទំព័រមួយដ៏អស្ចារ្យបំផុតដែលជានិមិត្តរូបនៃជ័យជំនះរបស់លទ្ធិវីរភាពបដិវត្ត និងភាពវៃឆ្លាតរបស់មនុស្ស ហើយបានកត់ត្រានៅក្នុងប្រវត្តិសាស្ត្រពិភពលោកគឺជាស្នាដៃដ៏អស្ចារ្យនៃសតវត្សរ៍ទី ២០ ព្រឹត្តិការណ៍មួយដ៏មានសារៈសំខាន់ជាអន្តរជាតិនិងមានអត្ថន័យសម័យយ៉ាងជ្រាលជ្រៅ" (ឆ្នាំនេះយើងប្រារព្ធខួបលើកទី ៤៥ឆ្នាំ) ។

ខណៈពេលដែលត្រូវប្រញាប់ជំនះពុះពាររាល់ផលវិបាកដ៏ធ្ងន់ធ្ងរបំផុតដោយសង្គ្រាមបន្សល់ទុក ប្រជាជនវៀតណាមនៅតែបន្តប្រឈមមុខនឹងសង្គ្រាមថ្មី។ ក្រោមការដឹកនាំរបស់

បក្ស កងទ័ព និងប្រជាជនយើងត្រូវស្តារសេដ្ឋកិច្ច - សង្គម បណ្តើរប្រយុទ្ធបណ្តើរដើម្បីការពារព្រំដែន ការពារឯករាជ្យជាតិនិងអធិបតេយ្យភាពទឹកដីដ៏ពិសិដ្ឋរបស់មាតុភូមិទន្ទឹមនឹងនេះ បំពេញកាតព្វកិច្ចអន្តរជាតិ ជួយប្រជាជនកម្ពុជាឱ្យរួចផុតពីអំពើប្រល័យពូជសាសន៍និងអនុវត្ត ដំណើររស់រានមានជីវិតឡើងវិញប្រទេសជាតិ។

ចំពោះនឹងតម្រូវការថ្មីនៃការអភិវឌ្ឍរបស់ប្រទេស ដើម្បីជំនះភាពមិនគ្រប់គ្រាន់នៃយន្តការផែនការកម្មប្រមូលផ្តុំនៃការិយានិយម អោបក្រសួបនិយមបាននាំឱ្យមានវិបត្តិសេដ្ឋកិច្ចសង្គមក្នុងបណ្តាឆ្នាំក្រោយសង្គ្រាម ដោយឈរលើមូលដ្ឋាន បូកសរុបការច្នៃប្រឌិតនិងនទានុវត្តថ្មីក្នុងការអនុវត្តជាក់ស្តែងរបស់ប្រជាជន បក្សយើងបានធ្វើការផ្លាស់ប្តូរថ្មីផ្នែកកសិកម្ម និងឧស្សាហកម្មបណ្តើរៗ និងមុនបង្អស់គឺការផ្លាស់ប្តូរថ្មីការទ្រិះរិះពិចារណាទ្រឹស្តីស្តីអំពីសង្គមនិយមនិងបង្កើតជាមាគ៌ាផ្លាស់ប្តូរថ្មីប្រទេសជាបណ្តើរ ៗ ។

មហាសន្និបាទទូទាំងប្រទេសលើកទី ៦ របស់បក្ស (ខែធ្នូឆ្នាំ ១៩៨៦) ដោយផ្អែកលើការវិភាគស៊ីជម្រៅអំពីស្ថានភាពរបស់ប្រទេស និងតាមរយៈដំណើរការនៃការរុករក ការធ្វើពិសោធន៍ជាក់ស្តែងដោយស្មារតី" សម្លឹងមើលចំការពិតនិងវាយតម្លៃចំការពិតការរៀបរាប់ចំការពិត "បានដាក់ចេញនូវមាគ៌ាផ្លាស់ប្តូរថ្មីសម្រាប់ប្រទេសដែលជាចំណុចរបត់សំខាន់មួយលើផ្លូវទៅកាន់សង្គម និយមនៅវៀតណាម។

មាគ៌ាផ្លាស់ប្តូរថ្មីបង្កើតឡើងបានឆ្លើយតបជាមួយតម្រូវការស្ថានភាពជាក់ស្តែង នៃប្រវត្តិសាស្ត្រ បង្ហាញភាពក្លាហាននិងការគិតច្នៃប្រឌិតរបស់បក្សកុម្មុយនិស្តវៀតណាម និងបើកយុគសម័យថ្មីសម្រាប់ការអភិវឌ្ឍរបស់ប្រទេសជាតិ។

បន្ទាប់ពីមហាសន្និបាតលើកទី៦ បក្សកុម្មុយនិស្តវៀតណាមបានបំពេញបន្ថែមនិងអនុវត្តជាក់ស្តែងជាបណ្តើរៗនៃមាគ៌ាផ្លាស់ប្តូរថ្មី ជាមួយនឹងខ្លឹមសារជាមូលដ្ឋាន និងខ្លឹមសារសំខាន់ៗដែលបានបង្ហាញនៅក្នុងកម្មវិធីនយោបាយ សម្រាប់ការកសាងប្រទេសជាតិក្នុងដំណាក់កាលអន្តរកាលឆ្ពោះទៅរកសង្គមនិយម (កម្មវិធីនយោបាយនៅឆ្នាំ១៩៩១ និងកម្មវិធីនយោបាយបំពេញបន្ថែម និងអភិវឌ្ឍន៍នៅឆ្នាំ២០១១) និងបណ្តាឯកសារសំខាន់ៗរបស់បក្សតាមរយៈបណ្តាសម័យសមាជ។

ក្នុងទសវត្សរ៍ទី៩០ នៃសតវត្សទី២០ ឆ្លងកាត់ការប្រឈមពីការដួលរលំនៃគំរូសង្គមនិយមពិតប្រាកដនៅសហភាពសូវៀត និងបណ្តាប្រទេសអឺរ៉ុបខាងកើត បក្សកុម្មុយនីស្តវៀតណាម ប្រជាជាតិវៀតណាមបានប្តេជ្ញាចិត្ត បន្តប្រកាន់ខ្ជាប់ដំណើរ និងច្នៃប្រឌិតនៅលើមាគ៌ាឆ្ពោះទៅរកសង្គមនិយមស្របតាមល័ក្ខខ័ណ្ឌ និងលក្ខណៈជាក់លាក់របស់វៀតណាម។

គណៈកម្មាធិការមជ្ឈឹមបក្សកុម្មុយនីស្តវៀតណាមចាប់ពីអាណត្តិទី៦ ដល់អាណត្តិទី១២ បានចេញសេចក្តីសម្រេចចិត្តជាច្រើនលើបណ្តាបញ្ហាជាមូលដ្ឋាន និងសំខាន់ៗរបស់បក្ស និង

ការអភិវឌ្ឍរបស់ប្រទេសជាតិ។ រដ្ឋសភាវៀតណាមបានរៀបចំកសាងប្រព័ន្ធច្បាប់ និងច្បាប់បង្កើតមូលដ្ឋានច្បាប់មួយថ្ងៃទៅមួយថ្ងៃកាន់តែបានព្រមៗជាមួយគ្នា និងសមស្របសម្រាប់ដំណើរការផ្លាស់ប្តូរថ្មី។

រដ្ឋាភិបាលអនុវត្តជាក់ស្តែង ជាបណ្តាយន្តការ គោលនយោបាយ និងដំណោះស្រាយជាក់លាក់ ដើម្បីគ្រប់គ្រងអភិបាល និងចាត់ចែងការងារកសាង និងអភិវឌ្ឍប្រទេសជាតិ។ក្នុងការកំណត់ និងដាក់ចេញមាគ៌ាផ្លាស់ប្តូរថ្មី បក្សកុម្មុយនីស្តវៀតណាមតែងតែកាន់ខ្ជាប់ និងអនុវត្តជាច្នៃប្រឌិតគោលការណ៍គ្រឹះ វិធានការវិចារវិទ្យានៃទស្សនៈ ម៉ាក្ស-លេនីន និងសតិអារម្មណ៍ហូជីមិញ។ និងបទពិសោធន៍ជាក់ស្តែងទាំងក្នុងនិងក្រៅប្រទេស ដោះស្រាយដ៏ល្អ ជាមួយបណ្តាចំណងទំនាក់ទំនងជាមូលដ្ឋាន ដូចជាការអភិវឌ្ឍខឿនសេដ្ឋកិច្ចទីផ្សារតាមទិសសង្គមនិយម; កសាងរដ្ឋនីតិរដ្ឋសង្គមនិយម "របស់ប្រជាជន ដោយសាប្រជាជន និងដើម្បីប្រជាជន"; រួមបញ្ចូលភ្ជាប់ជាមួយគ្នានូវការផ្លាស់ប្តូរថ្មីសេដ្ឋកិច្ច ជាមួយនឹងការផ្លាស់ប្តូរថ្មីនយោបាយ; រវាងកំណើនសេដ្ឋកិច្ចជាមួយការអនុវត្តវឌ្ឍនភាព និងយុត្តិធម៌សង្គម។ គួបផ្សំប្រកបដោយប្រសិទ្ធភាពនូវការអភិវឌ្ឍសេដ្ឋកិច្ច - សង្គមជាមួយវិស័យការពារជាតិ និងសន្តិសុខ រវាងការកសាងជាមួយការពារជាតិ; រវាងឯករាជ្យភាព ស្វ័យភាពនិងម្ចាស់ការសមាហរណកម្មអន្តរជាតិយ៉ាងសកម្ម។ រវាងបក្សដឹកនាំ រដ្ឋគ្រប់គ្រង ប្រជាជនធ្វើជាម្ចាស់ ។ល។ គ្មានឯកទិស គ្មានជ្រុលនិយម គ្មានអតនោមត មិនលោតពីបង្គោលមួយទៅបង្គោលមួយនោះទេ។

ជាក់ស្តែងបន្ទាប់ពីរយៈពេលជិត៣៥ឆ្នាំនៃការធ្វើផ្លាស់ប្តូរថ្មី ពីប្រទេសក្រីក្រមួយដែលមានសម្ភារៈ និងបច្ចេកទេស ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច - សង្គមដែលហួសសម័យ និងកម្រិតទាប រហូតមកដល់ពេលនេះប្រទេសវៀតណាម បានកើនឡើងក្លាយជាប្រទេសកំពុងអភិវឌ្ឍន៍ដែលមានប្រាក់ចំណូលមធ្យម; វប្បធម៌ និងសង្គមបន្តមានការអភិវឌ្ឍជីវភាពខាងសម្ភារៈ និងខាងស្មារតីរបស់ប្រជាជនត្រូវបានធ្វើឱ្យប្រសើរឡើង។ ការងារកសាងបក្ស និងប្រព័ន្ធនយោបាយមានរបត់មួយ; ប្លុកមហាសាមគ្គីភាពរបស់ប្រជាជាតិទាំងមូលបានពង្រឹងដោយឥតឈប់ឈរ; នយោបាយ សង្គមបានស្ថិរភាពសន្តិសុខជាតិ-ការពារជាតិឯករាជ្យភាពអធិបតេយ្យភាពត្រូវបានរក្សារឹងមាំ; ឋានៈ និងកិត្យានុភាពរបស់ប្រទេសត្រូវបានពង្រឹងកាន់តែខ្លាំងឡើងនៅលើឆាកអន្តរជាតិ។

រហូតមកដល់ពេលនេះ ប្រទេសវៀតណាមបានក្លាយជាប្រទេសមួយដែលមានប្រជាជនជិត ១០០ លាននាក់ ដែលមានប្រាក់ចំណូលជាមធ្យមចំនួន ២,៨០០ ដុល្លារអាមេរិកលើមនុស្សម្នាក់; បានចូលរួមនៅក្នុងអង្គការអន្តរជាតិជាច្រើន ក្លាយជាសមាជិកសកម្មនិងមានទំនួលខុសត្រូវក្នុងសកម្មភាពរបស់សហគមន៍អន្តរជាតិ។

ថ្មីៗនេះត្រូវបានជ្រើសតាំងដោយមហាសន្និបាតអង្គការសហប្រជាជាតិ ដោយមានសម្លេងគាំទ្រខ្ពស់និងស្ទើរតែដាច់ខាត ជាលើកទី២បានក្លាយជាសមាជិកមិនអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ។

ជាមួយនឹងសមិទ្ធផលដ៏អស្ចារ្យដែលសម្រេចបាន វៀតណាមមានមូលដ្ឋាន ដើម្បីបញ្ជាក់ថាប្រទេសវៀតណាម មិនដែលមានឱកាសមានសក្តានុពល ឋានៈនិងកិត្យានុភាពនាពេលបច្ចុប្បន្ននេះទេ។

សមមិត្ត និងជនរួមជាតិ

ការអនុវត្តជាក់ស្តែងប្រកបដោយភាពសម្បូរបែប រស់រវើក នៃបដិវត្តវៀតណាមក្នុងរយៈពេល៩០ឆ្នាំកន្លងមកនេះបានបង្ហាញថាការដឹកនាំត្រឹមត្រូវ ភ្លឺស្វាងរបស់បក្សគឺជាកត្តាឈានមុខគេក្នុងការកំណត់រាល់ជោគជ័យនៃបដិវត្ត បង្កើតឡើងសមិទ្ធផលជាច្រើននៅក្នុងប្រទេសវៀតណាម។

ម៉្យាងវិញទៀត តាមរយៈដំណើរការនៃការដឹកនាំបដិវត្តបក្សកុម្មុយនីស្តវៀតណាម បានហាត់ពត់លត់ដំ និងមួយថ្ងៃទៅមួយថ្ងៃកាន់តែមានភាពចាស់ទុំ សមនឹងតួនាទី និងបេសកកម្មដឹកនាំបដិវត្ត និងជំនឿជឿទុកចិត្ត ការរំពឹងទុករបស់ប្រជាជន។

ភាពជាក់ស្តែងនោះបញ្ជាក់ការពិតៈ នៅវៀតណាមមិនមានកម្លាំងនយោបាយណាមួយទៀត ក្រៅពីបក្សកុម្មុយនិស្តវៀតណាមដែលមានភាពក្លាហាន ប្រាជ្ញា បទពិសោធន៍ កិត្យានុភាព និងសមត្ថភាពដឹកនាំប្រទេស ឆ្លងកាត់រាល់ការលំបាក និងបញ្ហាប្រឈម នាំបដិវត្តរបស់ប្រជាជាតិយើងនឹងបន្តពីជ័យជំនះនេះដល់ជ័យជំនះផ្សេងៗទៀតនោះទេ។

ហើយនៅក្នុងដំណើរការនេះដែរ បក្សបានប្រមូលនិងរៀនមេរៀនដ៏មានតម្លៃជាច្រើន បង្កើតឡើងប្រពៃណីដ៏រុងរឿង ដែលសព្វថ្ងៃយើងមានទំនួលខុសត្រូវថែរក្សា និងពង្រីក។ វាជាប្រពៃណីនៃភាពស្មោះត្រង់គ្មានដែនកំណត់ ចំពោះផលប្រយោជន៍របស់ប្រទេសជាតិ និងវណ្ណៈ ប្រកាន់ខ្ជាប់ជាមួយទិសដៅ ឧត្តមគតិនៃឯករាជ្យភាពជាតិភ្ជាប់ជាមួយសង្គមនិយមផ្អែកលើមូលដ្ឋានលទ្ធិម៉ាក្ស - លេនីន និងសតិអារម្មណ៍ហូជីមិញ។

វាជាប្រពៃណីនៃការថែរក្សាឯករាជ្យ និងស្វ័យភាពតាមមាគ៌ា; ប្រកាន់ខ្ជាប់យ៉ាងម៉ឺងម៉ាត់ អនុវត្ត និងអភិវឌ្ឍភាពច្នៃប្រឌិតសទ្ធិម៉ាក្ស-លេនីន សំដៅទៅលើបទពិសោធន៍អន្តរជាតិ ដើម្បីកំណត់មាគ៌ាត្រឹមត្រូវ និងរៀបចំការអនុវត្តការងារបដិវត្តប្រកបដោយប្រសិទ្ធភាព។

វាជាប្រពៃណីនៃការផ្សារភ្ជាប់សាច់ឈាមរវាងបក្ស និងប្រជាជន ដែលតែងតែប្រកាន់យកការបម្រើប្រជាពលរដ្ឋគឺជារបៀបរស់នៅ និងគោលដៅខិតខំ។ វាជាប្រពៃណីនៃសាមគ្គីភាព ឯកភាពមានអង្គារចាត់ទាំង និងវិន័យមឹងម៉ាត់ដោយផ្អែកលើគោលការណ៍

ប្រមូលផ្តុំប្រជាធិបតេយ្យទិទៀននិងស្វ័យទិទៀននិងការស្រឡាញ់សមមិត្ត។ វាជាប្រពៃណី នៃសាមគ្គីភាពអន្តរជាតិភក្តីភាព ស្មោះសរ ផ្អែកលើគោលការណ៍និងគោលដៅថ្លៃថ្នូ។

ក្រឡេកមកមើលដំណើរ៩០ឆ្នាំនៃការកសាង ការប្រយុទ្ធ និងភាពចាស់ទុំរបស់បក្សកុម្មុយនិស្តវៀតណាម ហើយក្នុងឱកាសដ៏វិសេសវិសាលនេះយើងសូមថ្លែង ការដឹងគុណយ៉ាងជ្រាលជ្រៅទីបំផុតចំពោះលោកប្រធានហូជីមិញ - អគ្គមគ្គុទ្ទេសក៏មហាព្ធកៃនៃបក្ស និងប្រជាជនវៀតណាម ជាលោកគ្រូដ៏ឆ្នើមនៃបដិវត្តវៀតណាម - វីរៈបុរសនៃការរំដោះជាតិ និងឥស្សរជនវប្បធម៌ពិភពលោក។

លោកប្រធានហូជីមិញបានលះបង់អស់មួយជីវិតរបស់លោក ដើម្បីប្រជាជន ដើម្បីប្រទេស ដឹកនាំបក្ស និងប្រជាជនរបស់យើងដើម្បីទទួលបានជ័យជំនះដ៏រុងរឿង និងធ្វើអោយប្រទេសជាតិយើង ប្រជាជន និងប្រទេសជាតិយើងរុងរឿង״ ។

ប្រទេសជាតិមួយថ្ងៃទៅមួយថ្ងៃកាន់តែរីកចម្រើន ប្រជាជនមួយថ្ងៃកាន់តែសម្បូរសប្បាយរីករាយ បង្ហាញថាមនោគមវិជ្ជា បុព្វហេតុ សីលធម៌ ស្ទីលរបស់លោកប្រធានហូជីមិញគឺជាទ្រព្យសម្បត្តិដែលមិនអាចកាត់ថ្លៃបាន និងអំភូលភ្លឺដើម្បីបំភ្លឺផ្លូវសម្រាប់ប្រជាជាតិយើងបោះជំហានទៅមុខយ៉ាងរឹងមាំឆ្ពោះទៅអនាគត។

យើងចងចាំនិងដឹងគុណចំពោះគុណបំណាចដ៏ធំធេងរបស់ថ្នាក់ដឹកនាំបុព្វបុរសព្រឹទ្ធាចារបដិវត្ត គ្រួសារមានយុទ្ធជនពលីជីវិតអ្នកម្តាយវិរៈជន យុទ្ធជនពិការ យុទ្ធជនមានជំងឺ គ្រួសារមានគុណចំពោះជាតិ រួមទាំងជនរួមជាតិ យុទ្ធជនទូទាំងប្រទេស ដែលបានលះបង់ដោយអងអាចក្លាហាន ដើម្បីឯករាជ្យសេរីភាព អធិបតេយ្យភាព ឯកភាពនិងបូរណភាពទឹកដីនៃមាតុភូមិ ដើម្បីសង្គមនិយម និងកាតព្វកិច្ចអន្តរជាតិថ្លៃថ្នូនិងធ្វើការប្រយុទ្ធ ពលកម្មច្នៃប្រឌិត និងបានចូលរួមវិភាគទានយ៉ាងធំធេងចំពោះបុព្វហេតុបដិវត្តដ៏រុងរឿងរបស់ប្រជាជាតិយើង។

ដោយភាពថ្លៃថ្នូររបស់អ្នកបដិវត្តទាំងអស់ យើងនៅតែអាចនិយាយបានថា "បក្សរបស់យើងពិតជាមហាអស្ចារ្យម៉ែន! ប្រជាជនរបស់យើងពិតជាវីរបុរស!"

យើងចងចាំជានិច្ច និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការគាំទ្រ និងជួយឧបត្ថម្ភដ៏សំខាន់របស់ប្រជាជននៃបណ្តាប្រទេសសង្គមនិយម កម្លាំងរីកចម្រើន និងមិត្តភក្តិនៅទូទាំងទ្វីបទាំង៥ សម្រាប់បុព្វហេតុនៃការប្រយុទ្ធ ដើម្បីរំដោះប្រទេសជាតិ និងឯកភាព ជាតិនាពេលកន្លងមកក៏ដូចជាក្នុងការកសាង និងការពារមាតុភូមិនាពេលបច្ចុប្បន្ននេះ។

*សមមិត្ត និងជនរួមជាតិ*

បច្ចុប្បន្នបក្សទាំងមូល ប្រជាជនទាំងមូល និងកងទ័ពទាំងមូលកំពុងខិតខំអនុវត្តកម្មវិធីយោបាយរបស់បក្ស រដ្ឋធម្មនុញ្ញរដ្ឋ ជំរុញលើគ្រប់វិស័យ និងការធ្វើសមកាលកម្មផ្លាស់ប្តូរថ្មីធ្វើឧស្សាហូបនីយកម្ម, ទំនើបកម្ម, អភិវឌ្ឍសេដ្ឋកិច្ចទីផ្សារតាមបែបសង្គមនិយមបើកទ្វារ

ការធ្វើសមាហរណកម្មអន្តរជាតិអនុវត្តភារកិច្ចយុទ្ធសាស្ត្រពីរនៃការកសាង និងការពារមាតុភូមិ ដើម្បីប្រជាជនសំបូររុងរឿងប្រទេសរឹងមាំខ្លាំងក្លាប្រជាធិបតេយ្យយុត្តិធម៌និងអរិយធម៌។

នេះគឺជាបពហេតុបដិវត្តដ៏ធំធេងមហាអស្ចារ្យជា ការប្រយុទ្ធដ៏ធំមួយដូចដៃលោកប្រធានហូជីមិញបានមានប្រាសថា ប៉ុន្តែវាក៏ពិបាកនិងស្មុគស្មាញផងដែរ បរិបទនិងស្ថានភាពអន្តរជាតិនិងនៅក្នុងប្រទេសទន្ទឹមនឹងផ្នែកងាយស្រួល ឱកាសវាក៏មានការលំបាក និងការប្រឈមជា ច្រើនផងដែរ។ យើងប្រឈមមុខនឹងបញ្ហាថ្មីៗជាច្រើន ត្រូវដោះស្រាយរឿងស្មុគស្មាញ ជាច្រើនត្រូវដោះស្រាយ។ ស្ថានភាពនេះទាមទារអោយបក្សទាំងមូល ប្រជាជនទាំងមូល កងទ័ពទាំងមូលរបស់យើងជាងពេលណាៗទាំងអស់ ត្រូវលើកកម្ពស់ប្រពៃណីស្នេហាជាតិ និងបដិវត្តស្មារតីសាមគ្គីភាព និងទំនួលខុសត្រូវ ខិតខំដើម្បីជំនះរាល់ការលំបាក និងឧបសគ្គ ដើម្បីកសាងមាតុភូមិកាន់តែស្រស់ស្អាត និងស្រស់បំព្រងជាងនេះទៀត។

ការតស៊ូ និងភាពច្នៃប្រឌិតរបស់ប្រជាជនទាំងមូលគ្រប់ផ្នែកនិងថ្នាក់មូលដ្ឋាន វិស័យសេដ្ឋកិច្ច គឺជាកត្តាសំខាន់បំផុតសម្រាប់ការអភិវឌ្ឍប្រទេសរបស់យើង។

បក្សយើងត្រូវតែខិតខំជំរុញការកសាង និងកែតំរូវបក្សធ្វើឱ្យកាន់តែស្អាត និងខ្លាំងក្លារឹងមាំ បំពេញទំនួលខុសត្រូវគឺជាបុពហេតុបដិវត្តឈានមុខគេនៅក្នុងរយៈពេលថ្មី។

ចាប់តាំងពីសមាជបក្សលើកទី ១២ រហូតមកដល់បច្ចុប្បន្ន បក្សយើងបានលះបង់ពេលវេលា និងការខំប្រឹងប្រែងជាច្រើនក្នុងការកសាងបក្ស ចាត់ទុកការកសាងបក្សគឺជាការងារសំខាន់។នាពេលថ្មីៗនេះបក្សទាំងមូលបានអនុវត្តការកសាងនិងកែលំអរបក្សក្នុងស្មារតីនៃសេចក្តីសម្រេចចិត្តថ្នាក់កណ្តាល ៤ អាណត្តិទីXI និង XIIទទួលបានលទ្ធផល និងបទពិសោធន៍ដំបូងមានសារៈសំខាន់ណាស់រួមចំណែកក្នុងការការពារនិងបណ្តេញ រុញចោលភាពអវិជ្ជមានធ្វើអោយប្រសើរឡើងនូវសមត្ថភាពដឹកនាំ និង កម្លាំងប្រយុទ្ធរបស់បក្ស។

ក៏ប៉ុន្តែការកសាងបក្សនៅតែមានការងារជាច្រើនដែលត្រូវធ្វើ ជាពិសេសក្នុងការប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះនៃមនោគមវិជ្ជានយោបាយ សីលធម៌ របៀបរស់នៅ; ការបង្ហាញភាព "ប្រព្រឹកដោយខ្លួនឯង", "ការប្រែធាតុដោយរខ្លួនឯង"; អំពើពុករលួយខ្ជះខ្ជាការិយានិយម ឃ្លៀតឆ្ងាយពីប្រជាជន ...

កម្លាំងអមិតនៅតែស្វែងរកមធ្យោបាយដើម្បីបំផ្លាញបុព្វហេតុបដិវត្ត របស់ប្រជាជនយើង។ពួកគេព្យាយាមនិយាយបំភាន់មួលបង្កាច់និយាយអក្រកអំពីបក្សយើងនិងរដ្ឋយើងវាយប្រហារដោយផ្ទាល់លើមនោគមវិជ្ជាម៉ាកម្មវិធីនយោបាយបក្ស ញុះញង់ បំបែកបំបាកផ្ទៃក្នុងបក្ស ការបំបែកបក្ស និងរដ្ឋពីប្រជាជនប៉ុនប៉ុងធ្វើឱ្យបែកបាក់បក្សយើង របបយើងពីឬសពីខាងក្នុងគឺពឹសពុលនិងគ្រោះថ្នាក់។

ទិសដៅរួមនៃការស្ថាបនានិងកែតម្រូវបក្សគឺបន្តលើកកម្ពស់ប្រពៃណីល្អលើកស្ទួយនិងពង្រឹងលក្ខណៈបដិវត្តនិងភាពឈានមុខរបស់បក្ស។ កសាងបក្សពិតជាស្អាតស្អំរឹងមាំទាំងផ្នែកនយោបាយ មនោគមវិជ្ជា សីលធម៌ អង្គការចាត់តាំង កម្មាភិបាល ផ្លាស់ប្តូរថ្មីបែបផែនដឹកនាំ ពង្រឹងទំនាក់ទំនងសាច់ឈាមរវាងបក្សនិងប្រជាជន ធានាសម្រាប់បក្សមានសមត្ថភាពដឹកនាំ បុព្វហេតុអភិវឌ្ឍន៍ប្រទេស។

ក្នុងបរិបទដែលបក្សយើងជាបក្សកាន់អំណាចធ្វើប្រតិបត្តិការក្នុងបរិយាកាសអភិវឌ្ឍន៍សេដ្ឋកិច្ចទីផ្សារបើកចំហសមាហរណកម្ម កម្មាភិបាល និងសមាជិកបក្សដែលមានភារកិច ជាច្រើនប្រឈមនឹងការល្បួងលុយទ្រព្យសម្បត្តិកាទិញទឹកចិត្ត ញៀនអំណាចផ្ទាល់ខ្លួនកាន់តែច្រើន យើងត្រូវយកចិត្តទុកដាក់រក្សាលក្ខណៈ និងចរិតបដិវត្ត និងការឈានមុខរបស់បក្ស។

បើមិនបានយល់ដឹងរឿងនេះទេប្រសិនបើកម្មាភិបាលនិងសមាជិកបក្សមិនសកម្មនិងតស៊ូលត់ដំក្នុងការបណ្តុះបណ្តាលនិងសិក្សាវាងាយនឹងធ្លាក់ចុះខ្សោយនិងអន់ថយប្រែធាតុ។ បញ្ហានៃការថែរក្សារឹងមាំចរិតរបស់បក្ស- បក្សកុម្មុយនិស្តមួយជាបក្សបដិវត្តសុចរិត សកម្មភាព ដើម្បីបុព្វហេតុវណ្ណៈកម្មករ របស់ប្រជាជាតិដើម្បីផលប្រយោជន៍របស់ ប្រជាជនជាបញ្ហាមូលដ្ឋាននិងសំខាន់។

លោកប្រធានហូជីមិញធ្លាប់មានប្រសាសព្រមានថា៖" ប្រជាជាតិមួយបក្សមួយនិងមនុស្សមួយកាលពីម្សិលមិញមហាអស្ចារ្យមានប្រជាជនប្រាយធំមានការការទាក់ទាញដ៏អស្ចារ្យ, មិនប្រាកដថាថ្ងៃនេះនិងថ្ងៃស្អែកនៅតែ នឹងត្រូវបានគេស្រឡាញ់និងសរសើរនោះទេបើបេះដូងលែងមានភាពបរិសុទ្ធបើធ្លាក់ចូលទៅក្នុងបុគ្គលនិយម។

សេចក្តីសម្រេចចិត្តគណៈកម្មាធិការកណ្តាល ៤ អាណត្តិទីXI និង XII អំពីការកសាងបក្សបានអះអាងថា ត្រូវតែកសាងនិងកែតម្រូវបក្សដោយស្មារតីវិជ្ជមានប្តេជ្ញាចិត្តនិងរឹងមាំដើម្បីបង្កើតការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់បន្ថែមទៀតនៅលើគ្រប់ផ្នែក រារាំង និងរុញថយក្រោយ ភាពប្រែធាតុ រក្សាពង្រឹងភាពស្ថិតស្ថេរខ្ជាប់ខ្ជួនលើគោលដៅ ឧត្តមគតិបដិវត្ត; បង្កើនឯកភាពឆន្ទៈ និង សកម្មភាព។ ពង្រឹងអង្គការចាត់តាំងជិតស្និទ្ធ បង្កើនទំនាក់ទំនងជិតស្និទ្ធជាមួយប្រជាជន; លើកកម្ពស់ សមត្ថភាពដឹកនាំ និងសមត្ថភាពប្រយុទ្ធរបស់បក្ស ចាត់ទុកនេះជាបញ្ហាសំខាន់ជាលខ្វណៈអយុជីវិតរបស់បក្ស និងរបបរបស់យើង។

បក្សបដិវត្តបរិសុទមានមាគ៌ាត្រឹមត្រូវមានអង្គការចាត់តាំងរឹងមាំហ្មឹងម៉ាត់ បានរៀបចំយ៉ាងល្អ មានជួរមន្ត្រី សមាជិកបក្ស ស្អាត ស្អំ គំរូស្មោះត្រង់ ឧស្សាហ៍ព្យាយាមការងារភ្ជាប់សាច់ឈាមជាមួយប្រជាជន ដោយមានការគាំទ្រពីប្រជាជនបក្ស នោះមានអំណាចអប៉ះរាជ័យ គ្មានកម្លាំងណាអាចបញ្ឈប់បាននៅលើផ្លូវដឹកនាំប្រជាជនវឌ្ឍនភាព។

*សមមិត្ត និងជនរួមជាតិជាទីស្រឡាញ់*

ឆ្នាំនេះយើងប្រារព្ធពិធីថ្ងៃបង្កើតបក្សនៅពេលមានអត្ថន័យពិសេសៈ ឆ្នាំ ២០២០ គឺជាឆ្នាំចុងក្រោយនៃអាណត្តិសមាជលើកទី ១២ ឆ្នាំធ្វើសមាជបក្សគ្រប់ជាន់ថ្នាក់ រហូតដល់សមាជទូទាំងប្រទេសលើកទី ១៣ របស់បក្ស ឆ្នាំប្រារព្ធព្រឹត្តិការណ៍នយោបាយសំខាន់ៗជាច្រើន ឆ្នាំវៀតណាមដើរតួជាប្រធានអាស៊ាន និងជាសមាជិកមិនអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ។

ស្ថានភាពអន្តរជាតិ និងក្នុងប្រទេសបង្កើតឱកាស និងអំណោយផលជាច្រើន ក៏ប៉ុន្តែក៏បង្កការលំបាក និងឧបសគ្គជាច្រើនផងដែរ ទាមទារឱ្យបក្សទាំងមូល ប្រជាជនទាំងមូល និងកងទ័ពទាំងមូលត្រូវខិតខំប្រឹងប្រែង និងប្តេជ្ញាចិត្តខ្ពស់ ខិតខំបំពេញការងារប្រកបដោយជោគជ័យ ភារកិច្ចនៃឆ្នាំ ២០២០ ដោយផ្តោតលើការសំរេចបាននូវកំរិតខ្ពស់បំផុតនៃ ភារកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម។ ពង្រឹងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ជំរុញការអនុវត្តន៍នូវ វាយសំរុកជាយុទ្ធសាស្រ្តមានលក្ខណៈទម្លុះ

រៀបចំឡើងវិញរចនាសម្ព័ន្ធសេដ្ឋកិច្ចដែលផ្សារភ្ជាប់ជាមួយការផ្លាស់ ប្តូរថ្មីរូបមនកំណើន ធានាសន្តិសុខសុពលភាពសង្គម និងសុខមាលភាពសង្គម កែលំអរជីវភាពរស់នៅរបស់ប្រជាជន។

ថែរក្សាឯករាជ្យរឹងមាំ អធិបតេយ្យភាព និងបរិយាកាសសន្តិភាព ស្ថេរភាពសម្រាប់អភិវឌ្ឍ ប្រទេស ជំរុញទំនាក់ទំនងបរទេស។ ផ្តោតលើការរៀបចំសមាជបក្សគ្រប់ជាន់ថ្នាក់ដោយជោគជ័យឆ្ពោះទៅសមាជទូទាំងប្រទេសលើកទី ១៣ របស់បក្ស ភ្ជាប់ទៅនឹងការបន្តអនុវត្តសេចក្តីសម្រេចចិត្តមជ្ឈិម ៤, អាណត្តិទី X, អាណត្តិ XII ស្តីពី ការកសាងបក្ស សារាចរលេខ ០៥ របស់ការិយាល័យនយោបាយមជ្ឈឹមបក្ស ស្តីពីការជំរុញការ សិក្សា និងការអនុវត្ត មនោគមវិជ្ជា សីលធម៌ និងឥរិយាបថរបស់ហូជីមិញ។

ជាមួយក្តីសប្បាយរីករាយនិងមោទនភាព យើងជឿជាក់យ៉ាងមុតមាំថា បក្សកុម្មុយនីស្តវៀតណាមនឹងសំរេចជោគជ័យភារកិច្ចដ៏សំខាន់របស់ខ្លួន។ បក្សទាំងមូល ប្រជាជនទាំងមូល និងកងទ័ព ទាំងមូលបានរួបរួមគ្នាជាឯកច្ឆ័ន្ទចិត្តតែមួយឆន្ទៈតែមួយ និងខិតខំកសាងប្រទេសវៀតណាមសន្តិភាព ឯកភាព ឯករាជ្យ ប្រជាធិបតេយ្យ រុងរឿង និងវិបុលភាពបោះជំហានរឹងមាំឈានទៅសង្គមនិយម។

*រុងរឿងជាកម្មសិទ្ធិជានិច្ចរបស់ប្រជាជាតិវៀតណាមអរយ និងវីរភាព!*

*ជោយោ បក្សកុម្មុយនិស្តវៀតណាមរុងរឿង!*

*ជោយោ សាធារណរដ្ឋសង្គមនិយមវៀតណាម!*

*លោកប្រធានហូជីមិញដ៏មហិមាវ្យានៅជានិច្ចក្នុងបព្វហេតុរបស់យើង!*

*សូមអរគុណ ។*